# មជ្ឈមណ្ឌលជាតិលើកកំពស់សុខភាព

ព្រឹត្តិប័ត្រព័ត៌មាន លេខទី៤ | មករា-មីនា ២០២២










## សារៈសំខាន់នៃសារព្រមានសុខភាពជាភាសាខ្មែរ និងជារូបភាពលើកញ្ចប់ផលិតផលថ្នាំជក់

ការដាក់សារព្រមានសុខភាពលើកញ្ចប់ផលិតផលថ្នាំជក់ជាមធ្យោបាយ មានតម្លៃប្រសិទ្ធភាពបំផុតព្រោះ :

- ☆ សារព្រមានសុខភាពផ្ដល់ការអប់រំជានិច្ចអំពីផលប៉ះពាល់លើសុខភាពនិងព័ត៌មានស្ដីពីការលះបង់ទម្លាប់ប្រើប្រាស់ផលិតផលថ្នាំជក់ (២៤ម៉ោងក្នុងមួយថ្ងៃ ៧ថ្ងៃក្នុងមួយសប្ដាហ៍ ។ អ្នកជក់បារីមួយកញ្ចប់ក្នុងមួយថ្ងៃ និងកាន់កញ្ចប់បារី ២០ដងក្នុងមួយថ្ងៃគឺ ១៤០ដងក្នុងមួយសប្ដាហ៍)
- ☆ សារព្រមានលើកញ្ចប់ផលិតផលថ្នាំជក់នឹងទៅដល់គ្រប់អ្នកប្រើប្រាស់ថ្នាំជក់ទាំងអស់និងអ្នកនៅជិតអ្នកប្រើប្រាស់ ដូចជាគ្រួសារ មិត្តភក្ដិ និងសហការី
- ☆ ក្រសួងសុខាភិបាលជាអ្នកកំណត់សារ ហើយឧស្សាហកម្មថ្នាំជក់ជាអ្នកបោះពុម្ពសារព្រមានសុខភាពនេះ ។

## ហេតុអ្វីបានជាសារព្រមានលើកញ្ចប់ផលិតផលថ្នាំជក់ជារូបភាពកាន់តែធំ កាន់តែមានប្រសិទ្ធភាពខ្លាំង ?

សារព្រមានសុខភាពជារូបភាពធំ មានន័យថា សារនោះកាន់តែមានរូបភាពច្បាស់ ងាយយល់ ងាយស្រួលចំណាំ ងាយកត់សម្គាល់ និងបង្ហាញអំពីសារៈសំខាន់របស់សារ ទន្ទឹមនឹងនេះអាចកាត់បន្ថយឱកាសផ្សព្វផ្សាយពាណិជ្ជកម្មតាមរយៈកញ្ចប់ផលិតផលថ្នាំជក់ ។ ដូច្នេះ ការពង្រីកទំហំសារព្រមានសុខភាពជាភាសាខ្មែរ និងជារូបភាពលើកញ្ចប់ផលិតផលថ្នាំជក់នេះ ពិតជាមានសារៈសំខាន់ខ្លាំងណាស់ក្នុងការក្រើនរំលឹកពញ្ញាក់ស្មារតី ទៅដល់អ្នកប្រើប្រាស់ផលិតផលថ្នាំជក់ ដើម្បីឲ្យពួកគាត់ចាប់ផ្តើមនិងប្តេជ្ញាលះបង់ទម្លាប់ប្រើប្រាស់ថ្នាំជក់ឲ្យបានជោគជ័យ ក៏ដូចជាចូលរួមកាត់បន្ថយហានិភ័យនៃការឆ្លងជំងឺកូវីដ-១៩ ធ្ងន់ធ្ងរផងដែរ ។




## ការវិវឌ្ឍនៃសារព្រមានសុខភាពជាអក្សរ និងជារូបភាពលើកញ្ចប់ផលិតផលថ្នាំជក់ នៅក្នុងបណ្តាប្រទេសនានា

តាមគោលការណ៍ណែនាំសម្រាប់អនុវត្តមាត្រា១១ នៃអនុសញ្ញាស្តីពីការត្រួតពិនិត្យថ្នាំជក់របស់អង្គការសុខភាពពិភពលោក (WHO Framework Convention on Tobacco Control - WHO FCTC) បានណែនាំឲ្យបោះពុម្ពសារព្រមានសុខភាពឲ្យបានធំតាមដែលអាចធ្វើបាន និងរួមបញ្ចូលរូបភាពផងដែរ ដើម្បីឲ្យមានប្រសិទ្ធភាពក្នុងការផ្តល់ព័ត៌មានពីគ្រោះថ្នាក់នៃផលិតផលថ្នាំជក់ទៅកាន់អ្នកប្រើប្រាស់ បូករួមជាមួយនឹងការវេចខ្ចប់ដោយកញ្ចប់លាតដែលធ្វើឲ្យសារព្រមានសុខភាពជារូបភាពកាន់តែលេចធ្លោ ដែលជួយកាត់បន្ថយភាពទាក់ទាញរបស់ផលិតផលថ្នាំជក់ ។

ដើម្បីបង្កើនប្រសិទ្ធភាពនៃសារព្រមានសុខភាពនេះ សេចក្តីណែនាំនៃការអនុវត្តមាត្រាទី១១ និងទី១៣ នៃអនុសញ្ញាស្តីពីការត្រួតពិនិត្យថ្នាំជក់របស់អង្គការសុខភាពពិភពលោក បានលើកឡើងនូវការប្រើប្រាស់កញ្ចប់បារីលាត គឺដកចេញនូវភាពទាក់ទាញទាំងអស់នៃកញ្ចប់បារីដូចជា និមិត្តសញ្ញា ពណ៌ រូបភាព និងអក្សរផ្សេងៗនៅលើកញ្ចប់ លើកលែងតែឈ្មោះម៉ាក ដែលត្រូវសរសេរដោយប្រើប្រភេទអក្សរនិងទំហំដែលបានកំណត់ ។ នៅក្នុងឆ្នាំ២០១២ ប្រទេសអូស្ត្រាលីជាប្រទេសដំបូងគេដែលរឹតបន្តឹងដល់គ្រប់ម៉ាករបស់បារីទាំងអស់ឲ្យប្រើប្រាស់កញ្ចប់លាតនេះ ។

យោងទៅតាមរបាយការណ៍របស់អង្គការសុខភាពពិភពលោកបានឲ្យដឹងថា មកដល់ត្រឹមចុងឆ្នាំ២០២១ នេះ មានប្រទេសចំនួន១៧ ដែលបានបង្កើតឲ្យមានច្បាប់ស្តីពីការប្រើប្រាស់កញ្ចប់លាត ក្នុងនោះក៏មានប្រទេសថៃ និងសិង្ហបុរីផងដែរ ។ (WHO Report on the Global Tobacco Epidemic, 2021)

## សារព្រមានសុខភាពជាភាសាជាតិនិងរូបភាពនៅក្នុងបណ្តាប្រទេសអាស៊ាន

| ប្រទេស | ឆ្នាំនៃការដាក់ឲ្យដំណើរការ | ទីតាំង និងទំហំ |
|---|---|---|
| ប្រ៊ុយណេ | ២០០៨, ២០១២ | ខាងលើ ៧៥% ខាងមុខនិងខាងក្រោយ |
| កម្ពុជា | ២០១៦, ២០១៨, ២០២១ | ខាងលើ ៥៥% ខាងមុខនិងខាងក្រោយ |
| ឥណ្ឌូណេស៊ី | ២០១៤, ២០១៩ | ខាងលើ ៤០% ខាងមុខនិងខាងក្រោយ |
| ឡាវ | ២០១៨ | ខាងលើ ៧៥% ខាងមុខនិងខាងក្រោយ |
| ម៉ាឡេស៊ី | ២០០៩, ២០១៤ | ខាងលើ ៥០% ខាងមុខ និង ៦០% ខាងក្រោយ |
| មីយ៉ាន់ម៉ា | ២០១៦, ២០១៧, ២០១៨, ២០១៩, ២០២០, ២០២១ | ខាងលើ ៧៥% ខាងមុខនិងខាងក្រោយ |
| ហ្វីលីពីន | ២០១៦, ២០១៨, ២០២០, ២០២២ | ខាងក្រោម ៥០% ខាងមុខនិងខាងក្រោយ |
| សិង្ហបុរី | ២០០៤, ២០០៦, ២០១៣, ២០២០ | ខាងលើ ៥០% ខាងមុខនិងខាងក្រោយ |
| ថៃ | ២០០៥, ២០០៧, ២០១០, ២០១៤, ២០១៩ | ខាងលើ ៨៥% ខាងមុខនិងខាងក្រោយ |
| វៀតណាម | ២០១៣ | ខាងលើ ៥០% ខាងមុខនិងខាងក្រោយ |

ប្រភព: https://seatca.org/new-global-report-recognizes-pictorial-health-warnings-and-standardized-tobacco-packaging-in-asean/

## ការវិវឌ្ឍនៃសារព្រមានសុខភាពជាភាសាខ្មែរ និងជារូបភាពលើកញ្ចប់ផលិតផលថ្នាំជក់នៅក្នុងប្រទេសកម្ពុជា

ក្រសួងសុខាភិបាល ក្រោមការចង្អុលបង្ហាញ និងយកចិត្តទុកដាក់ដ៏ខ្ពង់ខ្ពស់ពីសំណាក់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** នៅក្នុងកិច្ចការពារសុខភាពប្រជាជនពីគ្រោះថ្នាក់នៃផ្សែងផលិតផលថ្នាំជក់ បានខិតខំប្រឹងប្រែងជំរុញការងារត្រួតពិនិត្យផលិតផលថ្នាំជក់ប្រកបដោយប្រសិទ្ធភាព ។ សម្រាប់ប្រទេសកម្ពុជា យោងតាមច្បាប់ស្តីពីការត្រួតពិនិត្យផលិតផលថ្នាំជក់ដែលបានអនុម័តដោយរដ្ឋសភានាខែមេសា និងដោយព្រឹទ្ធសភានាខែឧសភា ឆ្នាំ២០១៥ រដ្ឋាភិបាលបានចេញអនុក្រឹត្យស្តីពីការបោះពុម្ពសារព្រមានសុខភាពជាភាសាខ្មែរនិងជារូបភាពលើកញ្ចប់ផលិតផលថ្នាំជក់ ដែលមានទំហំ ៥៥% ដែលបានចូលជាធរមាននាខែកក្កដា ឆ្នាំ២០១៦ ។ ម្យ៉ាងទៀត សារព្រមានសុខភាពទំហំ ៥៥% ជាភាសាខ្មែរនិងជារូបភាពលើកញ្ចប់ផលិតផលថ្នាំជក់ ត្រូវផ្លាស់ប្តូររៀងរាល់ ១ឆ្នាំម្តងកំណត់ដោយសេចក្តីណែនាំរបស់រដ្ឋមន្ត្រីក្រសួងសុខាភិបាល ។

### ១. រូបភាពសារព្រមានសុខភាពជុំទី១

"ជក់បារីបណ្តាលឲ្យប៉ះពាល់ដល់ទារកយ៉ាងធ្ងន់ធ្ងរ" និង "ជក់បារីបណ្តាលឲ្យកើតជំងឺមហារីកសួត" ។



## ២. រូបភាពសារព្រមានសុខភាពជុំទី២

នៅឆ្នាំ ២០១៨ សារព្រមានសុខភាពជុំទី២ ត្រូវបានផ្លាស់ប្តូររូបភាពនិងខ្លឹមសារថ្មីគឺ "ជក់បារីបណ្តាលឲ្យកើតជំងឺដាច់សរសៃឈាមខួរក្បាល" និង "ជក់បារីបណ្តាលឲ្យកើតជំងឺសរសៃឈាមលើស្បែក"។

## ៣. រូបភាពសារព្រមានសុខភាពជុំទី៣

កាលពីថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២០ ក្រសួងសុខាភិបាលបានចេញលិខិតជូនដំណឹងដល់ក្រុមហ៊ុនផលិតផលថ្នាំជក់ក្នុងព្រះរាជាណាចក្រកម្ពុជា អំពីសេចក្តីណែនាំការបោះពុម្ពគំរូសារព្រមានសុខភាពជាភាសាខ្មែរនិងជារូបភាពជុំទី៣ ចំនួនពីរគឺ រូបភាព "ជក់បារីបណ្តាលឲ្យកើតជំងឺបេះដូង" និង "ជក់បារីបណ្តាលឲ្យកើតជំងឺហើមសួត"។




ឧបសម្ព័ន្ធទី៥
នៃប្រកាសលេខ : ០១៣ស / ប្រ.ក ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០១៦
ស្តីពីនីតិវិធីបោះពុម្ពសារព្រមានសុខភាពជាភាសាខ្មែរ និងជារូបភាពលើកញ្ចប់ផលិតផលថ្នាំជក់

គំរូប្លង់សារ និងរូបភាពព្រមានសុខភាពលើកញ្ចប់បារី
មាត្រដ្ឋាន : ១ / ១




ឧបសម្ព័ន្ធទី៦
នៃប្រកាសលេខ : ០១៣ស / ប្រ.ក ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០១៦
ស្តីពីនីតិវិធីបោះពុម្ពសារព្រមានសុខភាពជាភាសាខ្មែរ និងជារូបភាពលើកញ្ចប់ផលិតផលថ្នាំជក់

គំរូប្លង់សារ និងរូបភាពព្រមានសុខភាពលើកញ្ចប់បារី
មាត្រដ្ឋាន : ១ / ១




## សមិទ្ធផល កត្តាប្រឈម និងដំណោះស្រាយ

ក្នុងឆ្នាំ២០២១ កន្លងទៅនេះ យោងតាមរបាយការណ៍របស់មជ្ឈមណ្ឌលជាតិលើកកំពស់សុខភាពលើការចុះតាមដាននិងវាយតម្លៃអំពីការអនុវត្តការបោះពុម្ពសារព្រមានសុខភាពជាភាសាខ្មែរនិងជារូបភាពទំហំ៥៥% (ជុំទី២) នៅទូទាំង២៥ រាជធានី-ខេត្ត បានបង្ហាញថា ការបោះពុម្ពសារព្រមានសុខភាពជាភាសាខ្មែរនិងជារូបភាពទំហំ៥៥% សម្រេចបាន ៨២.១១%។

យ៉ាងណាមិញ ឧស្សាហកម្មផលិតផលថ្នាំជក់នៅតែបន្តប្រើប្រាស់គ្រប់វិធីសាស្ត្រ ដើម្បីឆ្លៀតឱកាសនិងព្យាយាមជ្រៀតជ្រែកក្នុងកិច្ចការងារត្រួតពិនិត្យផលិតផលថ្នាំជក់ ។ យោងតាមសេចក្តីណែនាំការបោះពុម្ពគំរូសារព្រមានសុខភាពជាភាសាខ្មែរនិងជារូបភាពជុំទី៣ ទំហំ៥៥% លើកញ្ចប់ផលិតផលថ្នាំជក់ ដែលក្រុមហ៊ុនផលិតផលថ្នាំជក់ទាំងអស់តម្រូវឲ្យ

ចាប់ផ្តើមអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខា និងតម្រូវឲ្យកញ្ចប់បារីទាំងអស់ដែលចរាចរនៅលើទីផ្សារ ត្រូវមានសារព្រមានសុខភាពជាភាសាខ្មែរនិងជារូបភាពថ្មី ដែលចូលជាធរមានចាប់ពីថ្ងៃទី១ ខែសីហា ឆ្នាំ២០២១ ដោយបានទុករយៈពេល ៩ខែ តាមការកំណត់ដោយអនុក្រឹត្យស្តីពីការបោះពុម្ពសារព្រមានសុខភាពជាភាសាខ្មែរឯរូបភាពលើកញ្ចប់ផលិតផលថ្នាំជក់ ។ ប៉ុន្តែក្រុមហ៊ុនផលិតផលថ្នាំជក់បានព្យាយាមស្នើសុំពន្យារពេលបោះពុម្ពផ្សាយសារព្រមានសុខភាពជាភាសាខ្មែរ និងរូបភាពលើកញ្ចប់ផលិតផលថ្នាំជក់ជុំទី៣ នេះទៅខែធ្នូ ឆ្នាំ២០២១ វិញ ក្រោមហេតុផលវិបត្តិសេដ្ឋកិច្ចក្នុងអំឡុងពេលនៃការរាតត្បាតជំងឺកូវីដ-១៩ និងការរៀបចំមិនទាន់ពេលវេលា ។ ក្នុងអំឡុងពេលមានការរាតត្បាតនៃជំងឺកូវីដ-១៩ ក្រសួងសុខាភិបាលកាន់តែបានយកចិត្តទុកដាក់បន្ថែមទៀត ក្នុងកិច្ចការពារប្រជាជនពីហានិភ័យនៃផ្សែងផលិតផលថ្នាំជក់ ដោយបានតាមដានជាប្រចាំលើការអនុវត្តច្បាប់ និងបានចាត់វិធានការច្បាប់ជាមួយក្រុមហ៊ុនថ្នាំជក់ចំនួនបួន ដែលល្មើសនឹងច្បាប់នៃការបោះពុម្ពសារព្រមានសុខភាពលើកញ្ចប់ផលិតផលថ្នាំជក់ វិធានការហាមឃាត់ការផ្សាយពាណិជ្ជកម្ម ការផ្សព្វផ្សាយលក់ និងការឧបត្ថម្ភកម្មវិធីដោយឧស្សាហកម្មថ្នាំជក់ ព្រមទាំងជំរុញការអនុវត្តទីកន្លែងគ្មានផ្សែងបារីឲ្យមានប្រសិទ្ធភាពក្នុងដំណាក់កាលរាតត្បាតនៃជំងឺកូវីដ-១៩ ។l



## ផ្សេងៗ ស្តីពី ការផ្លាស់ប្តូរឥរិយាបថនិងការលើកកម្ពស់សុខភាព

១) ព្រឹត្តិបត្រព័ត៌មាន របស់មជ្ឈមណ្ឌលជាតិលើកកំពស់សុខភាព (លេខទី៣ | វិច្ឆិកា-ធ្នូ ២០២១)

២) សៀវភៅណែនាំសម្រាប់ភ្នាក់ងារអប់រំ ផ្នែកទឹកស្អាតនិងអនាម័យ (យុទ្ធនាការ "មើលឃើញស្អាត មិនប្រាកដថាមានសុវត្ថិភាព")

៣) ការវាយតម្លៃរួមគ្នាលើតម្រូវការអប់រំនៅកម្ពុជា ក្នុងអំឡុងពេលមានជំងឺកូវីដ-១៩

៤) តើអ្វីជាឧបសគ្គក្នុងការផ្លាស់ប្តូរឥរិយាបថ? (ជាភាសាអង់គ្លេស)